# អត្ថបទតម្រែតម្រង់ទិសអំពីការធ្វើការនៅតុ WorkFirst

សម្រាប់ព័ត៌មានអំពីរបៀបផ្តល់ជូនការតម្រែតម្រង់ទិសរបស់ WorkFirst សូមមើល សៀវភៅណែនាំរបស់ WorkFirst 1.4.2។

| រូបភាពវីដេអូ | អក្សរ |
|---|---|
| 01<br> | ការណែនាំរបស់ WorkFirst សូមស្វាគមន៍ ក្នុងរយៈពេលពីរ ឬ បីនាទីទៀត យើងនឹងចែករំលែកព័ត៌មានអំពីជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត (ឬ TANF) និងកម្មវិធីរបស់ WorkFirst ។<br><br>TANF គឺជាកម្មវិធីផ្តល់សាច់ប្រាក់ ហើយ WorkFirst គឺជាកម្មវិធីដែលផ្តល់ឲ្យអ្នកនូវជម្រើសសម្រាប់សកម្មភាពដែលអាចជួយអ្នកស្វែងរកការងារ ឬធ្វើកិច្ចការផ្សេងៗទៀតដែលជួយអ្នកសម្រេចគោលដៅគ្រួសាររបស់អ្នក។<br><br>ប្រសិនបើអ្នកមិនទាន់មានទេ អ្នកនឹងទទួលកញ្ចប់ដែលមានកូនសៀវភៅ និងព័ត៌មានធនធានក្នុងមូលដ្ឋាន។<br><br>យើងអញ្ជើញអ្នកឲ្យសរសេរកំណត់ចំណាំ ឬសំណួរដែលអ្នកអាចនឹងមាន ដើម្បីយើងអាចពិភាក្សាចំណុចទាំងនោះជាមួយអ្នក ក្រោយពេលអ្នកមើលវីដេអូ។ |
| 02<br> | នៅរដ្ឋវ៉ាស៊ីងតោន មនុស្សពេញវ័យអាចទទួលបានសរុប 60 ខែ នៃជំនួយ TANF ក្នុងមួយជីវិតពួកគេ។<br><br>វាអាចរួមមានជំនួយជាសាច់ប្រាក់ដែលអ្នកបានទទួលនៅក្នុងរដ្ឋផ្សេងទៀត។ ក្នុងករណីជាក់លាក់ អ្នកអាចទទួលការបន្ថែមរយៈពេល។ |
| 03<br> | WorkFirst អាចភ្ជាប់អ្នកជាមួយដៃគូសហគមន៍ផ្សេងៗដែលផ្តល់បទពិសោធន៍ការងារ ការអប់រំ ការបណ្តុះបណ្តាល និងជំនួយស្វែងរកការងារធ្វើ។<br><br>យើងអាចនឹងមានដៃគូជាច្រើន និងធនធានដែលអាចប្រើប្រាស់បានជាច្រើន។ ភាពជាដៃគូសំខាន់បំផុតរបស់យើងគឺជាមួយអ្នក និងគ្រួសាររបស់អ្នក។ |

# អត្ថបទតម្រែតម្រង់ទិសអំពីការធ្វើការនៅតុ WorkFirst

04



យើងនឹងជួបជាមួយអ្នកដើម្បីពិភាក្សាអំពីស្ថានភាពរបស់អ្នក
ដើម្បីបង្កើតផែនការសម្រាប់ការចូលរួមរបស់អ្នកនៅក្នុងសកម្មភាព
WorkFirst ។

ផែនការនេះនឹងត្រូវរៀបចំឡើងសម្រាប់តែអ្នកប៉ុណ្ណោះ
ដោយផ្អែកលើគោលដៅ និងតម្រូវការជាក់លាក់របស់អ្នក
និងរបស់សមាជិកគ្រួសារអ្នក។

វាគឺសំខាន់សម្រាប់អ្នក ដែលត្រូវទាក់ទងមកយើងខ្ញុំ
ប្រសិនបើអ្នកមិនអាចចូលរួមក្នុងការណាត់ជួប
ឬសកម្មភាពដែលបានកំណត់រួច។
ផែនការរបស់អ្នកនឹងរួមបញ្ចូលព័ត៌មានអំពីរបៀបទាក់ទងមកយើងខ្ញុំ។

05



ប្រសិនបើអ្នកឈប់
ឬសម្រេចមិនចូលរួមក្នុងសកម្មភាពដែលបានយល់ព្រមរបស់អ្នក
ដោយមិនមានហេតុផលល្អ យើងអាចនឹងដាក់ទណ្ឌកម្ម។
ទណ្ឌកម្មកាត់បន្ថយការផ្តល់ប្រាក់ចំនួន 40%
ឬអាចបណ្តាលឲ្យបិទសំណុំរឿង TANF របស់អ្នក។

យើងមិនមានគោលដៅដាក់ទណ្ឌកម្មលើអ្នកទេ។
យើងមានគោលដៅជួយអ្នក
និងគ្រួសាររបស់អ្នកដើម្បីដោះស្រាយបញ្ហាប្រឈម។

06



មនុស្សគ្រប់គ្នាជួបបញ្ហានៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។
យើងយល់ថាស្ថានភាពទាំងនេះ អាចនឹងបង្កជាបញ្ហាដែលត្រូវធ្វើការ
និងគាំទ្រដល់គ្រួសាររបស់អ្នក។

វាជាការសំខាន់ដែលត្រូវចងចាំថា ការសុំ
និងការទទួលជំនួយអាចជាជំហ៊ានដំបូង
ក្នុងការធ្វើការឆ្លងកាត់ស្ថានភាពលំបាក។

យើងនឹងធ្វើការជាដៃគូជាមួយអ្នក និងផ្តល់ការគាំទ្រ
ដើម្បីអ្នកអាចធ្វើការឆ្ពោះទៅរកភាពជោគជ័យដែលអ្នកបានកំណត់ដោ
យផ្ទាល់ខ្លួន។

# អត្ថបទតម្រែតម្រង់ទិសអំពីការធ្វើការនៅតុ WorkFirst

07





នៅពេលអ្នកចូលរួមក្នុងសកម្មភាពរបស់ WorkFirst នោះអាចនឹងមានសេវាកម្មដែលអ្នកអាចប្រើប្រាស់បាន នៅក្នុងតំបន់របស់អ្នក រួមមានដូចជា ការជួយបង់ថ្លៃថែទាំកូនរបស់អ្នក។

អ្នកគួរស្នើសុំការថែទាំកូនឲ្យបានឆាប់តាមដែលអាចធ្វើបាន និងប្រាប់ឲ្យមិត្តរួមការងាររបស់អ្នកបានដឹង ប្រសិនបើអ្នកត្រូវការសេវាកម្មគាំទ្រផ្សេងទៀត ដើម្បីអ្នកត្រៀមខ្លួនរួចរាល់សម្រាប់ចូលរួមពេញលេញក្នុងសកម្មភាពរបស់ WorkFirst ។

អ្នកអាចស្នើសុំការថែទាំកូនតាមអ៊ីនធឺណិតតាម washingtonconnection.org ឬដោយទូរសព្ទទៅលេខ 1-844-626-8687 ។

អរគុណ! ជំហ៊ានបន្ទាប់គឺអ្នកត្រូវនិយាយជាមួយយើង អំពីជម្រើស និងបង្កើតផែនការរបស់អ្នកជាមួយគ្នា។